# សក្ខីកម្មអំពីសហគមន៍ផ្អែកលើចំណាប់អារម្មណ៍រួម

## សន្លឹកកិច្ចការសម្រាប់សមាជិកសហគមន

ការចែករំលែកសក្ខីកម្មអំពី "សហគមន៍ផ្អែកលើចំណាប់អារម្មណ៍រួម" របស់អ្នកនៅឯសវនាការនៃការបែងចែកតំបន់ឡើងវិញគឺជាវិធីដ៏មានឥទ្ធិពលក្នុងការរៀបចំផែនទីស្រុករបស់សហគមន៍របស់អ្នកសម្រាប់ទសវត្សរ៍ដែលនឹងមកដល់ខាងមុខ។ ជាមួយនឹងការតម្រៀមលក្ខណៈបន្តិចបន្តួច វាអាចងាយស្រួលធ្វើ។



### ស្រមៃថាការពិពណ៌នាអំពីសហគមន៍របស់អ្នកទៅមិត្តម្នាក់ដែលចង់ផ្លាស់ទីលំនៅទៅទីនោះ។

សហគមន៍របស់អ្នកអាចតូចដូចប្លុករបស់អ្នក សមាគមអ្នកជិតខាងរបស់អ្នក ឬបណ្តាញឪពុកម្តាយដែលបញ្ជូនកូនៗរបស់ពួកគេទៅសាលាតែមួយ ឬចូលរួមក្នុងក្រុមតូច (Little League ) តែមួយ។ ឬវាអាចមានការពង្រីក រួមទាំងអ្នករាល់គ្នានៅក្នុងទីក្រុង ឬខោនធីរបស់អ្នកដែលនិយាយភាសាដូចអ្នកដែរ អ្នករាល់គ្នាដែលជួលផ្ទះរបស់ពួកគេ ហើយពិបាកក្នុងការទូទាត់វិក្កយបត្រ ឬអ្នកគ្រប់គ្នានៅក្នុងផ្អែកនៃទីប្រជុំជនដែលទទួលរងនូវការវិនិយោគទាប និងសេវាកម្មមិនល្អ។

### តើសហគមន៍ផ្អែកលើចំណាប់អារម្មណ៍រួមគឺជាអ្វី?

សហគមន៍ផ្អែកលើចំណាប់អារម្មណ៍រួមគឺជាសហគមន៍របស់អ្នក។ វាអាចជាសង្កាត់រស់នៅ បណ្តាញ ឬក្រុមមនុស្សដែលមានចំណាប់អារម្មណ៍រួមនៅក្នុងសហគមន៍ ហើយអាចទទួលបានអត្ថប្រយោជន៍ពីការរួមគ្នាជាក្រុមទៅជាស្រុកតែមួយ។ គិតអំពីវិធីសាមញ្ញមួយដើម្បីពិពណ៌នាអំពីអ្វីដែលអ្នក និងអ្នកជិតខាងរបស់អ្នកចែករំលែកជាមួយគ្នា និងអ្វីដែលធ្វើឱ្យសហគមន៍របស់អ្នកមានតែមួយបើប្រៀបធៀបទៅនឹងសហគមន៍ជុំវិញ។ សូមចងចាំថា -- អ្នកគឺជាអ្នកជំនាញលើសហគមន៍របស់អ្នក!



### តើហេតុអ្វីបានជាសហគមន៍ផ្អែកលើចំណាប់អារម្មណ៍រួមមានសារៈសំខាន់?

ការរក្សាសហគមន៍ផ្អែកលើចំណាប់អារម្មណ៍រួមគឺជាគោលការណ៍សំខាន់មួយក្នុងការបែងចែកតំបន់ឡើងវិញ។ វាអាចមានប្រយោជន៍ជាពិសេសចំពោះសហគមន៍ដែលត្រូវបានគេបោះបង់ចោលជាប្រពៃណីពីដំណើរការនយោបាយ។ សមាជិកសហគមន៍អាចកំណត់និយមន័យសហគមន៍របស់ពួកគេតាមរយៈការប្រាប់រឿងផ្ទាល់ខ្លួនរបស់ពួកគេ និងការរៀបរាប់ពីកង្វល់របស់ពួកគេទៅកាន់អ្នកគូរព្រំប្រទល់ដែលកំពុងដឹកនាំដំណើរការបែងចែកតំបន់ឡើងវិញ។

ការរការរក្សាសហគមន៍ផ្អែកលើចំណាប់អារម្មណ៍រួមទាំងមូលនៅក្នុងដំណើរការបែងចែកតំបន់ឡើងវិញអាចជាលក្ខណៈវិនិច្ឆ័យនៃការបែងចែកតំបន់ឡើងវិញនៅក្នុងរដ្ឋរបស់អ្នក ឬត្រូវបានទទួលស្គាល់ដោយតុលាការថាជាការពិចារណាពាក់ព័ន្ធ។ សន្លឹកកិច្ចការនេះនឹងណែនាំអ្នកតាមរយៈធាតុផ្សំជាមូលដ្ឋានដើម្បីជួយអ្នកពិពណ៌នាអំពីសហគមន៍របស់អ្នកទៅអង្គភាពបែងចែកតំបន់ឡើងវិញរបស់អ្នកដែលអាចជាក្រុមប្រឹក្សាទីក្រុង ក្រុមប្រឹក្សាអ្នកមើលការខុសត្រូវផ្ទាល់ ឬសាលាប្រចាំស្រុកនិតិបញ្ញាតិរដ្ឋ ឬគណៈកម្មការបែងចែកតំបន់ឡើងវិញ។

**ព័ត៌មានជំនួយ៖ ពិនិត្យមើលថាតើអ្នកណាជាអ្នកទទួលបន្ទុកលើការបែងចែកតំបន់ឡើងវិញ។ ស្វែងយល់ថាតើមានពេលកំណត់ក្នុងការនិយាយដែរឬទេ។ រៀបចំគំរោងជាមុនផែ។**

ASIAN AMERICANS ADVANCING JUSTICE Common Cause

# ស្គ្រីប គំរូ

សួស្តី ខ្ញុំឈ្មោះ ________________________________. ។ ខ្ញុំបាន **[រស់នៅ/ធ្វើការ]** នៅក្នុង **[សហគមន៍/ទីក្រុង]** នៃ ________________________________ អស់យៈពេល ________ ឆ្នាំ។ ខ្ញុំចង់ឱ្យអ្នករក្សាសហគមន៍របស់ខ្ញុំ **[ឈ្មោះសហគមន៍]** ជាមួយគ្នា។

## [ពិពណ៌នាអំពីសហគមន៍របស់អ្នក...]

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

________________________________________________________________

**ដាក់ឈ្មោះ**សហគមន៍របស់អ្នក។ ពិពណ៌នាសហគមន៍របស់អ្នកដោយបញ្ជាក់ពីចំណាប់អារម្មណ៍ និងបុគ្គលិកលក្ខណៈរួមរបស់អ្នក។ នេះអាចរួមបញ្ចូលការពិពណ៌នាអំពីមនុស្សដែលរស់នៅក្នុងសហគមន៍របស់អ្នក រឿងរ៉ាវអំពីប្រវត្តិសាស្ត្រនិងវប្បធម៌របស់សហគមន៍អ្នក ឬតម្រូវការពិសេសរបស់សហគមន៍អ្នក។ មិនមានវិធីត្រូវឬខុសដើម្បីពិពណ៌នាអំពីសហគមន៍របស់អ្នកទេ។ គ្រាន់តែធ្វើឱ្យប្រាកដថានិយាយអំពី**អ្វីដែលភ្ជាប់មនុស្សនៅក្នុងសហគមន៍របស់អ្នក**។ គិតអំពីសំណួរទាំងនេះនៅពេលអ្នកបង្កើតរបៀបពិពណ៌នាសហគមន៍ផ្អែកលើចំណាប់អារម្មណ៍រួមរបស់អ្នក។



- ·តើនរណារស់នៅក្នុងសហគមន៍របស់អ្នក?
- ·តើពួកគេធ្វើការរកស៊ីអ្វីខ្លះសម្រាប់ការចិញ្ចឹមជីវិតរស់នៅ?
- ·តើលំនៅដ្ឋានប្រភេទណាដែលជាទូទៅ?
- ·តើសេវាកម្មរដ្ឋាភិបាលប្រភេទណាដែលប្រជាជនត្រូវការ?
- ·តើប្រជាជនស្ថិតក្នុងក្រុមសង្គមឬស៊ីវិលឬទេ?
- ·តើមានកន្លែងពិសេសណាមួយដែលប្រជាជនជួបជុំគ្នា ដូចជាមជ្ឈមណ្ឌលសហគមន៍ សាលារៀន ព្រះវិហារ ប្រាសាទ សហគមន៍រស់នៅជិតខាង ឬឧទ្យានណាដែរ?
- ·តើអ្នកមានចំណាប់អារម្មណ៍រួមនៅក្នុងបញ្ហានយោបាយក្នុងស្រុក ដូចជាការផ្តល់ថវិកាដល់សាលារៀន លទ្ធភាពទៅមន្ទីរពេទ្យ បញ្ហាសុខភាពឬបរិស្ថាន ឬបញ្ហាផ្សេងទៀតឬទេ?
- ·តើអ្នកមានពូជសាសន៍ ឬជាតិពិន្ធរួមឬទេ? ប្រវត្តិអន្តោប្រវេសន៍រួមឬទេ? ភាសានិយាយរួមឬទេ?
- ·តើសហគមន៍របស់អ្នកបានចែករំលែកបុគ្គលិកលក្ខណៈសេដ្ឋកិច្ចសង្គមរួម ដូចជាកម្រិតប្រាក់ចំណូល ឬកម្រិតអប់រំដែរឬទេ?
- ·តើសង្កាត់រស់នៅរបស់អ្នកមានការប្រារព្ធពិធី ឬប្រពៃណី ដូចជាពិធីបុណ្យតាមដងផ្លូវ ឬក្បួនដង្ហែរដែរឬទេ?
- ·តើអង្គការមិនរកប្រាក់ចំណេញ ឬអ្នកផ្តល់សេវាកណាខ្លះដែលបម្រើសហគមន៍?
- ·តើមាននិយោជកធំៗឬទេ? តើមានអាជីវកម្មខ្នាតតូចច្រើនឬទេ?
- ·តើរបៀបសហគមន៍របស់អ្នកប្រមូលផ្តុំគ្នាមានប្រវត្តិយ៉ាងដូម្តេចខ្លះ? តើសហគមន៍របស់អ្នកបានផ្លាស់ប្តូរតាមពេលវេលាយ៉ាងដូចម្តេច?

# ស្ដើប គំរូ

## <u>សហគមន៍ខ្ញុំមានទីតាំង៖</u>

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

អ្នកទទួលខុសត្រូវក្នុងការគូរផែនទីស្រុកផ្លូវការត្រូវដឹងទីតាំងរបស់សហគមន៍របស់អ្នក  ដើម្បីឱ្យពួកគេអាចរក្សាវាបានទាំងមូល និងនៅក្នុងស្រុកតែមួយ។ ទាំងនេះគឺជាសំណួរដែលនឹងជួយអ្នក**ពិពណ៌នាអំពីទីតាំងសហគមន៍របស់អ្នក**។



- តើផ្លូវ ឬព្រំប្រទល់ណាខ្លះដែលសម្គាល់ព្រំដែនសហគមន៍របស់អ្នក?
- តើមានទីសម្គាល់ទីតាំងសំខាន់ៗអ្វីខ្លះ៖ ទន្លេ ឧទ្យាន តំបន់លក់ទំនិញ ទីតាំងប្រវត្តិសាស្ត្រជាដើមឬទេ?
- តើកន្លែងណាខ្លះជាទីកន្លែងប្រមូលផ្តុំ និងអ្នកផ្តល់សេវាកម្មអ្វីខ្លះ៖ សាលារៀន មជ្ឈមណ្ឌលសហគមន៍ កន្លែងសាសនា និងទីភ្នាក់ងារសេវាសង្គម?
- តើព្រំប្រទល់ស្រុកនយោបាយបច្ចុប្បន្នបែងចែកសហគមន៍អ្នកឬទេ? ឬក៏ព្រំប្រទល់ស្រុកនយោបាយបច្ចុប្បន្នទាំងនោះរក្សាសហគមន៍របស់អ្នកនៅជាមួយគ្នា?

## <u>សហគមន៍ខ្ញុំប្រហាក់ប្រហែលនឹងសង្កាត់រស់នៅទាំងនេះ៖</u>

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

## <u>សហគមន៍ខ្ញុំខុសពីសង្កាត់រស់នៅទាំងនេះ៖</u>

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

# TEMPLATE SCRIPT

## អ្វីដែលធ្វើឱ្យសហគមន៍ខ្ញុំពិសេស៖

________________________________________

________________________________________

________________________________________

________________________________________

________________________________________

រំលេចពីបញ្ហានិងប្រវត្តិសហគមន៍ (ប្រាប់រឿងរ៉ាវផ្ទាល់ខ្លួន ប្រសិនបើអាច) ដែលជួយបង្ហាញពីសារៈសំខាន់នៃការមានមន្ត្រីជាប់ឆ្នោតដែលយល់ និងឆ្លើយតបទៅនឹងតម្រូវការសហគមន៍។ **ចែករំលែករឿងរ៉ាវ និងទិន្នន័យអំពីកង្វល់របស់សហគមន៍** ដើម្បីបង្ហាញពីរបៀបដែលអ្នកតំណាងដឹងឮពីសហគមន៍របស់អ្នក។

- តើសហគមន៍របស់អ្នកបានរួបរួមគ្នាដើម្បីគាំទ្រសេវាកម្មសំខាន់ៗ ដូចជាព័ត៌មានបកប្រែបន្ថែម ឬមណ្ឌលសុខភាពនៅក្នុងសង្កាត់រស់នៅរបស់អ្នកឬទេ?
- តើអ្នកបានទទួលជ័យជម្នះជាមួយគ្នា ឬបង្កើតប្រពៃណីជាមួយគ្នាឬទេ?
- តើមានផលប៉ះពាល់អ្វីខ្លះដែលបណ្តាលមកពីសំឡេងរបស់អ្នកមិនត្រូវបានអើពើ ដូចជាសុខភាពខ្សោយដែល បណ្តាលមកពីការបំពុលពីរោងចក្រ ឬផ្លូវហាយវេក្បែរនោះ? តើមានឧបសគ្គអ្វីខ្លះក្នុងការដោះស្រាយបញ្ហាទាំងនេះ?

## នៅក្នុងសេចក្តីសន្និដ្ឋាន...

________________________________________

________________________________________

________________________________________

________________________________________

________________________________________



**សង្កត់ធ្ងន់ថាហេតុអ្វីបានជាសហគមន៍របស់អ្នកមានសារៈសំខាន់ក្នុងការរក្សាទុកជាមួយគ្នានៅក្នុងផែនទីស្រុកថ្មី។** សូមថ្លែងអំណរគុណដល់សមាជិកនៃអង្គភាពបែងចែកតំបន់ឡើងវិញ (ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាសាលារៀន គណៈកម្មការជាដើម) ផ្តល់ដល់ពួកគេនូវសក្ខីកម្ម និង ឯកសារជាលាយលក្ខណ៍អក្សរ ទទួលស្គាល់សមាជិក សហគមន៍ និងដៃគូនៅក្នុងការចូលរួម និងបង្ហាញគោលដៅឡើងវិញ។